# ប្រឡងប្រចាំខែមេសា ថ្នាក់ទី៦

មុខវិជ្ជា៖ ភាសាខ្មែរ (សមត្ថភាពអាន)

* Indicates required question

1. សូមបំពេញឈ្មោះរបស់ប្អូន *

អំណាន៖ សេចក្ដីថ្លៃថ្នូរ

សេចក្ដីថ្លៃថ្នូរជាគុណសម្បត្តិមួយដ៏ប្រសើរថ្លៃថ្លា ដែលមនុស្សគ្រប់រូបប្រាថ្នាចង់បាន។ សេចក្ដីថ្លៃថ្នូរនឹងកើតមានចំពោះមនុស្សទាំងឡាយណា ដែលមានភាពស្មោះត្រង់ ប្រកាន់សច្ចៈ យុត្តិធម៌ មានវិន័យ សីលធម៌ និងមានមនសិការវិជ្ជាជីវៈ។ ប្រទេសណា ដែលសម្បូរដោយមនុស្សថ្លៃថ្នូរ ប្រទេសនោះនឹងទទួលបាននូវកេរ្តិ៍ឈ្មោះប្រសើរលើ ពិភពលោក។

មនុស្សមានសីលធម៌សំដៅលើមនុស្ស ដែលមានឥរិយាបថល្អប្រពៃ ចេះគោរព ច្បាប់ ចេះជួយគ្នាទៅវិញទៅមក និងចេះរួមរស់ជាមួយគ្នាប្រកបដោយសន្តិភាព។ សីលធម៌ប្រៀបដូចជាចង្កូតជួយតម្រង់មនុស្សឱ្យដើរតាមផ្លូវល្អ ដែលកើតចេញពីការចេះ គោរពប្រតិបត្តិដំបូន្មានល្អៗ ទំនៀមទម្លាប់ប្រពៃណី វិន័យ បទបញ្ញត្តិ និងច្បាប់នៅក្នុង សង្គម។

មនុស្សមានមនសិការវិជ្ជាជីវៈ គឺជាមនុស្សដែលចេះស្រឡាញ់ការងារ យកចិត្តទុក ដាក់នឹងការងារ មានស្មារតីទទួលខុសត្រូវនឹងការងារ ខំប្រឹងប្រែងធ្វើការងារ ខិតខំស្រាវជ្រាវ ច្នៃប្រឌិត និងធ្វើឱ្យការងារនោះមានការរីកចម្រើន ។

ចំណេះវិជ្ជាក៏ជួយមនុស្សឱ្យមានសេចក្ដីថ្លៃថ្នូរដែរ ព្រោះចំណេះវិជ្ជាធ្វើឱ្យមនុស្ស ចេះគិតពិចារណា ស្គាល់អំពើល្អ អំពើអាក្រក់ អ្វីគួរធ្វើ អ្វីមិនគួរធ្វើ ។ ចំណេះវិជ្ជាកើត ឡើងដោយសារការខិតខំព្យាយាមរៀនសូត្រ ។ ដើម្បីឱ្យជីវិតកាន់តែមានតម្លៃថែមទៀតនោះ មនុស្សម្នាក់ៗ គប្បីខិតខំកសាងអំពើល្អ សុចរិតទៀងត្រង់ ។ អំពើទាំងនោះស្ដែងចេញឡើង តាមរយៈការជួយសង្គ្រោះអ្នកដទៃ ការមិនរើសអើង មិនរំលោភសិទ្ធិអ្នកដទៃ ការប្រកាន់យកសច្ចធម៌ជាដើម ។

សេចក្ដីថ្លៃថ្នូរធ្វើឱ្យមនុស្សមានកេរ្តិ៍ឈ្មោះក្រអូប មានកិត្តិយសថ្កុំថ្កើងរស់នៅសុខសាន្ត ។ សេចក្ដីថ្លៃថ្នូរប្រៀបដូចជាគ្រឿងអលង្ការ ធ្វើឱ្យមនុស្សមានសោភ័ណ។ ដូច្នេះ មនុស្សគ្រប់រូបត្រូវប្រកាន់យកសេចក្ដីថ្លៃថ្នូរ ទើបយើងអាចរស់នៅប្រកបដោយសុភមង្គលបាន ។



LIVEWORKSHEETS

2. ១. តើពាក្យ "សេចក្តីថ្លៃថ្នូរ" ក្នុងអត្ថបទនេះមានន័យដូចម្តេច? * 1 point

*Check all that apply.*

- [ ] ក. ការមានទ្រព្យសម្បត្តិស្តុកស្តម្ភ
- [ ] ខ. តម្លៃនៃបុគ្គលដែលកើតចេញពីគុណធម៌ និងអំពើល្អ
- [ ] គ. ការមានអំណាចលើអ្នកដទៃ
- [ ] ឃ. ការស្លៀកពាក់ខោអាវថ្លៃៗ

3. ២. តើពាក្យ "មនសិការវិជ្ជាជីវៈ" សំដៅលើអ្វី? * 1 point

*Check all that apply.*

- [ ] ក. ការធ្វើការងារដើម្បីតែប្រាក់ខែ
- [ ] ខ. ការចេះដឹងផ្នែកបច្ចេកទេសខ្ពស់
- [ ] គ. ស្មារតីទទួលខុសត្រូវ និងការស្រឡាញ់ឱ្យតម្លៃលើការងាររបស់ខ្លួន
- [ ] ឃ. ការបង្ខំចិត្តធ្វើការងារតាមបញ្ជា

4. ៣. តើពាក្យ "សុចរិត" មានន័យផ្ទុយនឹងពាក្យអ្វី? * 1 point

*Check all that apply.*

- [ ] ក. ទៀងត្រង់
- [ ] ខ. ទុច្ចរិត
- [ ] គ. យុត្តិធម៌
- [ ] ឃ. បរិសុទ្ធ

5. ៤. តើពាក្យណាខ្លះជាពាក្យ "ន័យដូច" នឹងពាក្យ "ចំណេះវិជ្ជា"? * 1 point

*Check all that apply.*

- [ ] ក. វិជ្ជា, ការចេះដឹង, វិទ្យាសាស្ត្រ
- [ ] ខ. សីលធម៌, វិន័យ
- [ ] គ. កិត្តិយស, កេរ្តិ៍ឈ្មោះ
- [ ] ឃ. សុភមង្គល, សន្តិភាព



LIVEWORKSHEETS

6. ៥. តើអ្វីទៅដែលប្រៀបដូចជា "ចង្កូត" តម្រង់មនុស្សឱ្យដើរតាមផ្លូវល្អ? * 1 point

*Check all that apply.*

- [ ] ក. ប្រាក់កាស
- [ ] ខ. សីលធម៌
- [ ] គ. អំណាច
- [ ] ឃ. រូបសម្បត្តិ

7. ៦. យោងតាមអត្ថបទ តើមនុស្សមានមនសិការវិជ្ជាជីវៈមានលក្ខណៈសម្បត្តិដូចម្ដេច? * 1 point

*Check all that apply.*

- [ ] ក. ធ្វើការងារឱ្យតែរួចពីដៃ
- [ ] ខ. ចេះស្រឡាញ់ការងារ និងខិតខំស្រាវជ្រាវច្នៃប្រឌិត
- [ ] គ. ចាំតែស្ដាប់បង្គាប់មេកើយ
- [ ] ឃ. ធ្វើការងារដើម្បីកិត្តិយសផ្ទាល់ខ្លួន

8. ៧. តើចំណេះវិជ្ជាជួយមនុស្សឱ្យមានសេចក្ដីថ្លៃថ្នូរតាមរបៀបណា? * 1 point

*Check all that apply.*

- [ ] ក. ធ្វើឱ្យមនុស្សចេះអួតអាង
- [ ] ខ. ធ្វើឱ្យមនុស្សចេះរកប្រាក់បានច្រើន
- [ ] គ. ធ្វើឱ្យមនុស្សចេះពិចារណា ស្គាល់ខុសត្រូវ ល្អអាក្រក់
- [ ] ឃ. ធ្វើឱ្យមនុស្សមានឋានៈខ្ពង់ខ្ពស់ក្នុងសង្គម

9. ៨. តើអត្ថបទនេះប្រៀបធៀប "សេចក្ដីថ្លៃថ្នូរ" ទៅនឹងអ្វី? * 1 point

*Check all that apply.*

- [ ] ក. គ្រឿងអលង្ការ
- [ ] ខ. សម្លៀកបំពាក់
- [ ] គ. ម្ហូបអាហារ
- [ ] ឃ. ផ្ទះសម្បែង


LIVEWORKSHEETS

10. ៩. ដើម្បីឱ្យជីវិតកាន់តែមានតម្លៃ តើមនុស្សម្នាក់ៗគប្បីធ្វើអ្វី? * 1 point

*Check all that apply.*

- [ ] ក. សន្សំទ្រព្យសម្បត្តិឱ្យបានច្រើន
- [ ] ខ. កសាងអំពើល្អ និងមានភាពសុចរិតទៀងត្រង់
- [ ] គ. ស្វែងរកតែភាពល្បីល្បាញ
- [ ] ឃ. ដើរតួជាអ្នកដឹកនាំគេជានិច្ច

11. ១០. តើប្រទេសដែលសម្បូរដោយមនុស្សថ្លៃថ្នូរនឹងទទួលបានអ្វី? * 1 point

*Check all that apply.*

- [ ] ក. ទទួលបានជំនួយពីបរទេស
- [ ] ខ. ទទួលបានកេរ្តិ៍ឈ្មោះប្រសើរលើពិភពលោក
- [ ] គ. ទទួលបានអាវុធទំនើបៗ
- [ ] ឃ. មានផ្ទៃដីធំជាងមុន

12. ១១. យោងតាមអត្ថបទ តើកត្តាអ្វីខ្លះដែលនាំឱ្យប្រទេសមួយមាន "កេរ្តិ៍ឈ្មោះប្រសើរ" លើពិភពលោក? * 1 point

*Check all that apply.*

- [ ] ក. ការមានសព្វាវុធទំនើបៗ និងកងទ័ពខ្លាំងពូកែ
- [ ] ខ. ការសម្បូរទៅដោយធនធានធម្មជាតិ និងរ៉ែមានតម្លៃ
- [ ] គ. ការសម្បូរទៅដោយប្រជាពលរដ្ឋដែលមានសេចក្តីថ្លៃថ្នូរ
- [ ] ឃ. ការមានផ្ទៃដីធំទូលាយ និងអគារខ្ពស់ៗ

13. ១២. តើពាក្យ "សច្ចធម៌" ក្នុងអត្ថបទនេះ ចង់សម្តៅលើអ្វី? * 1 point

*Check all that apply.*

- [ ] ក. ធម៌ដែលនាំឱ្យមានទ្រព្យសម្បត្តិ
- [ ] ខ. ធម៌នៃសេចក្តីពិត ឬការប្រកាន់យកភាពត្រឹមត្រូវ
- [ ] គ. ការជឿជាក់លើព្រេងវាសនា
- [ ] ឃ. ការចេះមន្តអាគមវិសេសវិសាល



LIVEWORKSHEETS

14. ១៣. ក្នុងឃ្លា "សីលធម៌ប្រៀបដូចជាចង្កូត" តើពាក្យ "ចង្កូត" ក្នុងន័យធៀបនេះមានតួនាទីអ្វី? * 1 point

*Check all that apply.*

- [ ] ក. សម្រាប់តែបង្កើនល្បឿនជីវិតឱ្យលឿន
- [ ] ខ. សម្រាប់លម្អឱ្យជីវិតមើលទៅស្អាត
- [ ] គ. សម្រាប់កំណត់ទិសដៅ និងតម្រង់ជីវិតឱ្យដើរផ្លូវល្អ
- [ ] ឃ. សម្រាប់បញ្ឈប់សកម្មភាពគ្រប់យ៉ាង

15. ១៤. តើមនុស្សដែលមាន "ស្មារតីទទួលខុសត្រូវ" ចំពោះការងារ ហៅថាមនុស្សបែបណា? * 1 point

*Check all that apply.*

- [ ] ក. មនុស្សមានមនសិការវិជ្ជាជីវៈ
- [ ] ខ. មនុស្សមានចំណេះវិជ្ជាខ្ពង់ខ្ពស់
- [ ] គ. មនុស្សមានអំណាច
- [ ] ឃ. មនុស្សមានទ្រព្យសម្បត្តិ

16. ១៥. តើការ "មិនរើសអើង និងមិនរំលោភសិទ្ធិអ្នកដទៃ" បង្ហាញពីតម្លៃអ្វីខ្លះ? * 1 point

*Check all that apply.*

- [ ] ក. ការចង់បង្ហាញភាពខ្លាំង
- [ ] ខ. ការកសាងអំពើល្អ និងការផ្តល់តម្លៃដល់ជីវិត
- [ ] គ. ការធ្វើតាមព្រឹត្តិការណ៍សង្គម
- [ ] ឃ. ការភ័យខ្លាចចំពោះច្បាប់

17. ១៦. បើបុគ្គលម្នាក់ "ខិតខំស្រាវជ្រាវ និងច្នៃប្រឌិត" តើនឹងមានលទ្ធផលអ្វីកើតឡើងដល់ការងារ? * 1 point

*Check all that apply.*

- [ ] ក. ការងារនៅដដែល មិនប្រែប្រួល
- [ ] ខ. ការងារកាន់តែស្មុគស្មាញ និងលំបាក
- [ ] គ. ការងារទទួលបានការរីកចម្រើន
- [ ] ឃ. ការងារនឹងត្រូវបញ្ចប់ដោយជោគជ័យភ្លាមៗ


LIVEWORKSHEETS

18. ១៧. ក្នុងន័យអត្ថបទ តើគ្រឿងលម្អដែលធ្វើឱ្យមនុស្សមាន "សោភ័ណ" (សម្រស់) ពិតប្រាកដគឺអ្វី? * 1 point

*Check all that apply.*

- [ ] ក. មាស ប្រាក់ និងពេជ្រ
- [ ] ខ. សម្លៀកបំពាក់ម៉ាកល្បីៗ
- [ ] គ. សេចក្ដីថ្លៃថ្នូរ
- [ ] ឃ. ការវះកាត់កែសម្ផស្ស

19. ១៨. តើពាក្យ "មនសិការ" ជានាមសព្ទដែលមានន័យថាដូចម្ដេច? * 1 point

*Check all that apply.*

- [ ] ក. ការគិតឃើញតាមអារម្មណ៍
- [ ] ខ. ការដឹងខុសត្រូវដែលកើតចេញពីក្នុងចិត្ត
- [ ] គ. ការយល់សប្តិឃើញរឿងល្អ
- [ ] ឃ. ការធ្វើតាមមតិភាគច្រើន

20. ១៩. តើ "ភាពសុភមង្គល" ក្នុងជីវិតអាចកើតមានទៅបាន លុះត្រាតែមនុស្សម្នាក់ៗប្រកាន់យកអ្វី? * 1 point

*Check all that apply.*

- [ ] ក. ប្រកាន់យកសេចក្ដីថ្លៃថ្នូរ
- [ ] ខ. ប្រកាន់យកការចង់ចាញ់ចង់ឈ្នះ
- [ ] គ. ប្រកាន់យកតែផលប្រយោជន៍ផ្ទាល់ខ្លួន
- [ ] ឃ. ប្រកាន់យកភាពឯកោ

21. ២០. តើពាក្យ "ទៀងត្រង់" មានន័យដូចនឹងពាក្យអ្វីក្នុងចំណោមពាក្យខាងក្រោម? * 1 point

*Check all that apply.*

- [ ] ក. រៀចវេរ
- [ ] ខ. បរិសុទ្ធ
- [ ] គ. ស្មោះត្រង់
- [ ] ឃ. ស្លូតបូត



LIVEWORKSHEETS

This content is neither created nor endorsed by Google.

Google Forms



LIVEWORKSHEETS